**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៦ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារសិក្សាប្លង់គោលអភិវឌ្ឍក្រុងព្រះសីហនុ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**ស ម្រ េ ច**

**ប្រការ ១ :** បង្កើតក្រុមការងារសម្រាប់សិក្សា និងលើកគម្រោងប្លង់គោល ដើម្បីអភិវឌ្ឍក្រុងព្រះសីហនុ ក្នុងគោលដៅស្ថាបនាក្រុងនេះ ឱ្យទៅជាប៉ូលសេដ្ឋកិច្ច និងទេសចរណ៍សំខាន់មួយ នៅព្រះរាជាណាចក្រកម្ពុជា ដែលក្រុមការងារនេះមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម **យឹម ឈុលឡា** | ប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ប្រធាន |
| ២- ឯកឧត្តម **ហេង វង្សប៊ុនឆាត** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | អនុប្រធាន |
| ៣- ឯកឧត្តម **នុត ណារ៉ាង** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |

www.pheakdeylaw.com

| | | | |
|---|---|---|---|
| ៤- ឯកឧត្តម | ឡៅ សុខា | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥- ឯកឧត្តម | ឌី យ៉ាច | អនុប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| ៦- ឯកឧត្តម | សុខ ចិន្តា | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៧- ឯកឧត្តម | ចឡឺ ចិរស្សុត | អគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- ឯកឧត្តម | ម៉ម សុផារណា | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៩- ឯកឧត្តម | ជា ច័ន្ទដេត | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន | សមាជិក |
| ១០-ឯកឧត្តម | តាន់ ស៊ីនតូ | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១- ឯកឧត្តម | ឌា សុផ្លា | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល | សមាជិក |
| ១២- ឯកឧត្តម | សូ ម៉ារ៉ា | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៣- ឯកឧត្តម | សយ សុខាន់ | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល | សមាជិក |
| ១៤- ឯកឧត្តម | អ៊ុក សូមេត្ត | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ១៥- ឯកឧត្តម | លឹម ទាន់ | អគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៦- ឯកឧត្តម | សាយ ហាក់ | អភិបាលក្រុងព្រះសីហនុ | សមាជិក |
| ១៧- លោក | គី សុភាត់ | អគ្គនាយករង អគ្គនាយកដ្ឋានសាធារណការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៨- លោក | ច័ន្ទ មុន្នីនាថ | អគ្គនាយករង អគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងបរិស្ថាន | សមាជិក |
| ១៩- លោក | ម៉េង សំគ្គីនារ៉ា | ប្រធាននាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |

**ប្រការ ២ :** ក្រុមការងារសិក្សាប្លង់គោលអភិវឌ្ឍក្រុងព្រះសីហនុមានភារកិច្ចដូចតទៅ :

- ពិចារណាសិក្សាស្រាវជ្រាវ លើកគម្រោងសុរុបឆ្ពោះទៅការអភិវឌ្ឍ ដែលឆ្លើយតបនឹងបច្ចេកទេសខ្ពស់សម្រាប់បំរុងទទួលកំណើនប្រជាជនពីចំនួនបច្ចុប្បន្ន ១៣០.០០០ នាក់ ទៅ ២.០០០.០០០ នាក់ នៅឆ្នាំ ២០៤០ ។

www.pheakdeylaw.com

- ទំនាក់ទំនងជាមួយដៃគូរួមមាន ស្ថាបត្យករ អ្នកវិនិយោគ កម្មសិទ្ធិករដីធ្លី ក្រុមហ៊ុន ដែលអាចជាសម្បទានិកសេវាសាធារណៈនាអនាគត ស្រង់យកគំនិតដើម្បីកិច្ចការអភិវឌ្ឍនេះ ។
- រៀបចំតាក់តែងសេចក្តីព្រាងបទដ្ឋានចាំបាច់ទាំងឡាយ ដើម្បីឆ្លងគណៈរដ្ឋមន្ត្រីឱ្យបានឆាប់រហ័សជាពិសេស ៖
  - បទដ្ឋានស្តីពីគំរូមគ្គុទ្ទេសក៍សរុបសម្រាប់ក្រុងព្រះសីហនុ
  - បទដ្ឋានស្តីពីប្លង់អភិវឌ្ឍន៍លំអិតសម្រាប់បណ្តាតំបន់ទាំង ១៤
  - បទដ្ឋានស្តីពីការបង្កើតអាជ្ញាធរជាតិសម្រាប់ដឹកនាំការរៀបចំ និងអភិវឌ្ឍន៍ក្រុងព្រះសីហនុ
  - បទដ្ឋានស្តីពីការរកប្រភពចំណូលសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធ

**ប្រការ ៣ ៖** សមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ ៖** ក្រុមការងារនេះ អាចបង្កើតអនុក្រុមការងារជំនាញមួយចំនួនតាមការចាំបាច់ ។

**ប្រការ ៥ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល ៖*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com